ជូនចំពោះមាតាបិតា / អ្នកមើលថែ

***ស្តីពី:  បញ្ជីការធំលូតលាស់ខាងបឋមវ័យអូស្ត្រាលី (AEDI)***

សាលារៀនរបស់យើងនឹងចូលរួមនៅក្នុងការប្រមូលនូវព័ត៌មានជាតិ ស្តីអំពីការធំលូតលាស់នៃកុមារវ័យក្មេង។ ការប្រមូលនូវព័ត៌មាននេះហៅថាបញ្ជីការធំលូតលាស់ខាងបឋមវ័យអូស្ត្រាលី (AEDI)។ រដ្ឋាភិបាលអូស្ត្រាលីបានបូរផ្តាច់ថវិកាចំនួន១៥.៩លានដុល្លា សំរាប់ការធ្វើឲ្យចេញនូវ AEDI ដែលកំពុងចាត់ចែងឡើងដោយមជ្ឈមណ្ឌលសំរាប់សុខភាពកុមារសហគមន៍ (នៅមន្ទីរពេទ្យកុមារ Royal Children's Hospital) ក្រុងម៉ែលប៊ន ហើយនិងមជ្ឈមណ្ឌលស្រាវជ្រាវសំខាន់មួយរបស់មជ្ឈមណ្ឌលស្រាវជ្រាវកុមារ Murdoch (Murdoch Childrens Research Centre) ក្នុងការរួមដៃគ្នាជាមួយវិទ្យាស្ថាន Telethon សំរាប់ការស្រាវជ្រាវសុខភាពកុមារ (Telethon Institute for Child Health Research) នៅទីក្រុង Perth។

AEDI គឺជាបញ្ជីផែកមើលដែលមានសំណួរច្រើនជាង១០០ ហើយត្រូវបំពេញដោយគ្រូបង្រៀនរបស់កូនលោកអ្នក។ បញ្ជីផែកមើល AEDI សំគាល់រកមើលផ្នែកទាំងប្រាំនៃការធំលូតលាស់របស់កុមារ:

- សុខភាពផ្នែករាងកាយ និងសុខុមាលភាព
- សមត្ថភាពខាងសង្គម
- ភាពធំដឹងក្តីខាងផ្លូវចិត្ត
- ជំនាញលើភាសា និងការដឹងយល់ ហើយនិង
- ជំនាញការទាក់ទងគ្នា ហើយនិងចំណេះដឹងទូទៅ។

គោលបំណងនៃការប្រមូលយកព័ត៌មាននេះគឺដើម្បី:

- ជួយដល់សហគមន៍ឲ្យបានយល់អំពីបែបយ៉ាងណាដែលកូនរបស់គេធំលូតលាស់ មកទល់នឹងពេលដែលគេមានវ័យចូលរៀន
- ជួយដល់សាលារៀន ភ្នាក់ងារក្នុងតំបន់ ហើយនិងអ្នកវិជ្ជាជីវៈផ្នែកធំលូតលាស់ខាងបឋមវ័យនៃកុមារភាព ក្នុងការធ្វើការជាមួយគ្នាដើម្បីកែលំអលទ្ធផលសំរាប់កុមារទាំងអស់នៅក្នុងសហគមន៍។

បញ្ជីសំណួរនឹងបានបំពេញដោយគ្រូបង្រៀនរបស់កូនលោកអ្នកនៅ ____________________។ វាមិនតម្រូវឲ្យយកកូនរបស់លោកអ្នកចេញពីថ្នាក់រៀនឡើយ។ ទាំងលោកអ្នក និងកូនរបស់លោកអ្នកមិនចាំបាច់ធ្វើអ្វីឡើយ។

ទិន្នន័យសង្ខេបបានពីការវិភាគនៃបញ្ជីសំណួរទាំងនេះនឹងមានផ្តល់សំរាប់សហគមន៍ ដោយយោងទៅលើក្រុមកុមារទាំងមូលក្នុងវិធីមួយដែលគ្មាននរណាម្នាក់អាចនឹងសំគាល់ដឹងពីកូនរបស់លោកអ្នកឡើយ។

ទិន្នន័យក៏អាចដាក់រួមជាមួយនឹងព័ត៌មានពីអង្គការឯទៀតផងដែរ ក្នុងគោលបំណងដើម្បីឲ្យបានយល់កាន់តែប្រសើរឡើងពីបែបយ៉ាងណាដែលកម្មវិធី និងគោលការណ៍ទាំងឡាយសំរាប់កុមារវ័យក្មេងអាចមានដំណើរការល្អប្រសើរ។ នៅក្រោមច្បាប់ឯកជនបច្ចុប្បន្ន គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យសំគាល់ដឹងពីទិន្នន័យរបស់កូនលោកអ្នកឡើយ។

ប្រសិនបើលោកអ្នកចង់ទទួលព័ត៌មានច្រើនថែមទៀតអំពី AEDI សូមបើកមើលវ៉ិបសាយ www.aedi.org.au ឬទាក់ទងជាមួយមជ្ឈមណ្ឌលផ្គត់ផ្គង់ជាតិ AEDI នៅមន្ទីរពេទ្យកុមារ ក្រុងម៉ែលប៊ន តាមទូរស័ព្ទលេខ 1300 558 422 ឬទាក់ទងជាមួយសាលារៀន។

**ប្រសិនបើលោកអ្នកមិនចង់ឲ្យគេប្រមូលយកព័ត៌មានពីកូនរបស់លោកអ្នកទេ សូមទាក់ទងជាមួយសាលារៀន។**

នេះគឺជាឱកាសដ៏ល្អមួយសំរាប់មាតាបិតា សាលារៀន ហើយនិងភ្នាក់ងារឯទៀតដើម្បីធ្វើការរួមគ្នាជាប្រយោជន៍សំរាប់កុមាររបស់យើង។ សូមអរគុណលោកអ្នកចំពោះការជួយផ្គត់ផ្គង់ដល់ AEDI។

នាយកសាលា